**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិបណ្តុះបណ្តាល
National Training Board (NTB)

# កំណត់ហេតុអង្គប្រជុំ
# លើកទី ៥ របស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល

នៅឆ្នាំពីរពាន់ដប់ ខែកុម្ភៈ ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំលេខ ៤២៤ ជាន់ទី៤ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំគណៈកម្មាធិការជាតិបណ្តុះបណ្តាល National Training Board ( NTB ) ក្រោមអធិបតីភាព **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលមានសមាសភាពចូលរួម និងរបៀបវារៈនៃអង្គប្រជុំ (សូមជូនភ្ជាប់មកជាមួយ )។

<u>របៀបវារៈទី១</u>

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជំនាញការជាតិ និងអន្តរជាតិ ដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ និងមានប្រសាសន៍ដោយរំលឹកឡើងវិញ ក្នុងសភាពការណ៍ពេលបច្ចុប្បន្ននេះការងារបណ្តុះបណ្តាលវិជ្ជាជីវៈគឺកាន់តែមានសារៈសំខាន់ណាស់ ហើយគណៈកម្មាធិការនេះមានបេសកកម្ម និងភារកិច្ចជាច្រើន ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ច។ ជាក់ស្តែងចាប់ពីឆ្នាំ ២០១១ តទៅនឹងមានសិស្សចប់វិទ្យាល័យចំនួនប្រហែល ២០០,០០០ នាក់ក្នុងមួយឆ្នាំ ដែលជាកត្តាមួយទាមទារឲ្យរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ជំនាញវិជ្ជាជីវៈដល់យុវជន យុវនារី ដើម្បីឲ្យក្លាយទៅជាធនធានមនុស្សដែលឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារការងារ។

<u>របៀបវារៈទី២</u>

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឲ្យឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល បានរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការអនុវត្តវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមមូលនិធិពិសេសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ហើយឯកឧត្តម **ពេជ សោភ័ន** បានបង្ហាញលើចំនុចមួយចំនួនដូចតទៅ៖

ដោយសារគោលនយោបាយ **ឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើឲ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរ រីកចំរើន និងអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស។ ប៉ុន្តែក្នុងឆ្នាំ២០០៨ វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោកធ្វើឲ្យវិស័យមួយចំនួនបាននឹងកំពុងទទួលរងផលប៉ះពាល់រួមមាន រោងចក្រកាត់ដេរសំលៀកបំពាក់ ទេសចរណ៍ អចលនទ្រព្យ និងសំណង់ ដោយសារផ្នែកទាំងនេះទាក់ទងទៅនឹងទុនវិនិយោគ និងទីផ្សារបរទេស។

ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃវិបត្តិនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងវេទិការជាមួយឯកជនបានណែនាំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យសហការការងារជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំមូលនិធិពិសេសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងគោលនយោបាយការងារមួយចំនួនដើម្បីរៀបចំដោះស្រាយបញ្ហា និងវិបត្តិ ចំពោះកម្មករ កម្មការនី និង យុវជន យុវនារី ដែលបាត់បង់ និងគ្មានការងារធ្វើ។

មូលនិធិពិសេសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នេះបានចាប់ផ្តើមដំណើរការពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ នៅទូទាំង ២៤រាជធានី-ខេត្ត ហើយបានបញ្ចប់សព្វគ្រប់នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩។ គោលបំណងនៃមូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺដើម្បី៖

១. ផ្តល់សំណាញ់សុវត្ថិភាព ក្នុងកម្រិតអប្បបរមាមួយជូនដល់កម្មករ កម្មការនីដែលបាត់បង់ការងារធ្វើដោយ ផ្តល់ការឧបត្ថម្ភលើការហូបចុកចំនួន ៤,០០០រៀល ក្នុងមួយថ្ងៃ និងការស្នាក់នៅចំនួន ៤០,០០០រៀល ក្នុង១ខែ។

២. បង្កើនផលិតភាព និងបង្កើតការងារ តាមរយៈផ្តល់ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ដែលទីផ្សារត្រូវការ ជូនដល់កម្មករ កម្មការនី។

ជាលទ្ធផលនៃការបណ្តុះបណ្តាលមូលនិធិពិសេសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សរុបមានចំនួន ១,៤៩៥វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៤០,១៤០នាក់ ( ស្ត្រី ២២,៥៨៦នាក់ ) ក្នុងនោះមាន សេវាកម្មចំនួន ៤៧១វគ្គ ដែលមានសិក្ខាកាមចំនួន ៩,៤២០នាក់ ( ស្ត្រី ៥,២១៥នាក់ ) និងផ្នែកកសិកម្មចំនួន ១,០២៤វគ្គ ដែលមានសិក្ខាកាមចំនួន ៣០,៧២០នាក់ ( ស្ត្រី ១៧,៣៧១នាក់ )។ សម្រាប់អង្គភាពដែលទទួលមូលនិធិពិសេសរបស់សម្តេចតេជោធ្វើការបណ្តុះបណ្តាលមានទាំងអស់ចំនួន ៧៧អង្គភាព ដែលក្នុងនោះគ្រឹះស្ថានសាធារណៈចំនួន ៣៩អង្គភាព សមាគមចំនួន ២០អង្គភាព និងអង្គការផ្សេងៗចំនួន ១៨អង្គភាព។ មូលនិធិពិសេសរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចំណាយថវិកាសម្រាប់ការបណ្តុះបណ្តាលសរុបមានចំនួន ៣១,២០០,០០០,០០០រៀល ។

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបណ្តុះបណ្តាលជំនាញខាងលើ មូលនិធិពិសេសរបស់សម្តេចតេជោបានផ្តល់ថវិកាបន្ថែមទៀតដល់គ្រប់អង្គភាពបណ្តុះបណ្តាលទាំងអស់ សម្រាប់បើកវគ្គបណ្តុះបណ្តាលគំនិត ឬហៅថា " សហគ្រិនភាព " ដែលមានរយៈពេលមួយសប្តាហ៍ ក្នុងគោលបំណងជួយសិក្ខាកាមឲ្យមានគំនិតប្រកបមុខរបរដោយខ្លួនឯង ហើយមានសមត្ថភាពក្នុងការរៀបចំធ្វើផែនការ និងការគ្រប់គ្រងមុខជំនាញផ្ទាល់។ មិនតែប៉ុណ្ណោះសិក្ខាកាមអាចខ្ចីឥណទានខ្នាតតូច នៃមូលនិធិពិសេសយកទៅបង្កើតមុខរបរដោយខ្លួនឯងបាន។

មូលនិធិពិសេសនេះជាផ្នែកមួយនៃនយោបាយទីផ្សារការងារសកម្ម ដែលរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ប្រកាន់យក។ មូលនិធិនេះពិតជាបានជួយឲ្យកម្មករ កម្មការនីដែលបានរំសាយពីរោងចក្រ និងយុវជន យុវនារី ដែលគ្មានការងារធ្វើឆ្លងផុតពីការលំបាកក្នុងកំឡុងពេលវិបត្តិសេដ្ឋកិច្ចព្រមទាំងទទួលបាននូវជំនាញវិជ្ជាជីវៈមួយពិតប្រាកដ ។ ហើយមូលនិធិនេះក៏ទទួលបានការគាំទ្រយ៉ាងខ្លាំងពីកម្មករ កម្មការនី យុវជន យុវនារី សហជីព អ្នកជំនាញការជាតិ អន្តរជាតិ អ្នកសេដ្ឋកិច្ច និងអ្នកវិភាគ។

ជាចុងក្រោយ ឯកឧត្តមបានសំណូមពរ សូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងបញ្ជូនសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទៅ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យលទ្ធភាព និងមេត្តាបន្តឲ្យមាននូវមូលនិធិពិសេសនេះតទៅទៀត។

<u>របៀបវារៈទី៣</u>

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឲ្យ ឯកឧត្តម **ឡៅ ហ៊ឹម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជានាយកប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងជាប្រធានសម្របសម្រួលគម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) ធ្វើការរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីលទ្ធផលនៃការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ឆ្នាំ២០០៦-២០០៩ ហើយឯកឧត្តម **ឡៅ ហ៊ឹម** បានបង្ហាញលើចំនុចមួយចំនួនដូចតទៅ៖

គម្រោងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) បានចាប់ផ្តើមអនុវត្តន៍នៅឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ មានរយៈពេល ៥ឆ្នាំ។ ចំពោះការបណ្តុះបណ្តាលមានរយៈពេល ៤ឆ្នាំ គឺចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ សម្រាប់ការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់នេះត្រូវបានចំណាយថវិកាមកដល់បច្ចុប្បន្នសរុបចំនួន ៤,៥៤៤,៩៩៩.៥៧ USD ។

គម្រោងនេះធ្វើការបណ្តុះបណ្តាលសាកល្បង ៧ខេត្តនៅក្នុង ២១០ឃុំ ដែលការបណ្តុះបណ្តាលមានលក្ខណៈ ៣ប្រភេទគឺ តាមសហគមន៍ តាមសហគ្រាស និង តាមមជ្ឈមណ្ឌល។ ក្នុង ១ឃុំ ត្រូវបានទទួលថវិកាសម្រាប់ការបណ្តុះបណ្តាលចំនួន ៥,០០០ដុល្លា/ឆ្នាំ សម្រាប់សិក្ខាកាម ២២២នាក់។ គម្រោងបានកំណត់ចំនួនសិក្ខាកាមជាក្រុមគោលដៅសម្រាប់ការបណ្តុះបណ្តាលមានចំនួនសរុប ១២០,០០០នាក់ ជាក់ស្តែងលទ្ធផលនៃការបណ្តុះបណ្តាលសិក្ខាកាម

មានចំនួនរហូតដល់ ១៥៤,៦៦៩នាក់ ដែលការបណ្តុះបណ្តាលនេះលើសពីផែនការរបស់គម្រោងមានចំនួន ៣៤,៦៦៩នាក់។ មូលហេតុដែលលើសនេះដោយសារការបណ្តុះបណ្តាលនៅក្នុង ១វគ្គមានតែ ៣៥នាក់ ប៉ុន្តែសហគមន៍មានតម្រូវការច្រើន ហើយពួកគាត់បានស្នើសុំចូលរៀនបន្ថែម មានន័យថា ១វគ្គ មានសិក្ខាកាមគឺ ៣៦ ឬ ៣៧នាក់ សរុបជារួមឃើញថាចំនួនសិក្ខាកាមកើនឡើង តែទឹកប្រាក់សម្រាប់ការបណ្តុះបណ្តាលនៅដដែល ។ ដោយសារកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) ទទួលបានជោគជ័យទាំង ៧ខេត្ត ADB នឹងពង្រីកការបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ទូទាំង ២៤រាជធានី-ខេត្ត តាមរយៈការផ្តល់គម្រោងថ្មីគឺ គម្រោងពង្រឹងវិស័យ TVET។

**របៀបវារៈទី៤**

បន្ទាប់មក ឯកឧត្តម **ឡៅ ហ៊ីម** បានរាយការណ៍សង្ខេបជូនអង្គប្រជុំស្តីពីគម្រោងសាកល្បងបច្ចេកទេសក្រោយប្រមូលផល និងកម្មវិធីស្ពានចម្លងបន្តជំនាញសម្រាប់អ្នកជនបទក្រីក្រ ចាប់ផ្តើមពីខែកក្កដា ឆ្នាំ២០០៩ ដល់ខែកក្កដា ឆ្នាំ២០១២ ប្រើប្រាស់ថវិកាចំនួន ២,០០០,០០០ USD ហើយធ្វើការសាកល្បងលើគ្រឹះស្ថានសិក្សា ៤ ក្នុងនោះមាន មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តសៀមរាប វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត និងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដោយជ្រើសរើសអ្នកភូមិចំនួន ៣,០០០នាក់ នៅក្នុង ៤៤ឃុំ ។ **ឯកឧត្តម** បានលើកយកគម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈTVET I មានថវិកាសរុបចំនួន ២៧,៥លាន USD រួមមានជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ២៤.៥០លាន USD និងថវិកាបដិភាគពីរាជរដ្ឋាភិបាលចំនួន ៣លាន USD សម្រាប់ដំណើរការរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៥។ ក្នុងនោះ STVET I មាន ៣សមាសភាគគឺ ទី១ ពង្រីក និងធ្វើឲ្យកម្មវិធីវិញ្ញាបនបត្រ និងសញ្ញាបត្រកាន់តែប្រសើរឡើង ទី២ ពង្រីក និងធ្វើឲ្យកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់កាន់តែប្រសើរឡើង និងទី៣ ពង្រឹងសមត្ថភាពធ្វើផែនការ និងការគ្រប់គ្រង TVET ។ បន្ទាប់មក **ឯកឧត្តម** បានបង្ហាញនូវផែនការអនាគតសម្រាប់រយៈពេល ១៥ឆ្នាំទៅមុខ។

**ឯកឧត្តម សុខ អាន**

-មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើគម្រោងជួយកសិករក្រោយពេលប្រមូលផល ហើយបានស្នើសុំឲ្យ ឯកឧត្តម **ឡៅ ហ៊ីម** ធ្វើអត្ថាធិប្បាយបន្ថែមឲ្យកាន់តែច្បាស់លើគម្រោងនេះទៅអង្គប្រជុំ។

**ឯកឧត្តម ឡៅ ហ៊ីម**

ពាក់ព័ន្ធនឹងគម្រោងនេះ បញ្ហាដែលយើងរកឃើញថា ការផលិតរបស់កសិករមិនទាន់ចេះចងក្រងជាក្រុមនៅឡើយទេ មានន័យថា ការផលិតអ្វីមួយរបស់ពួកគាត់ដូចគ្នា នៅពេលដែលប្រមូលផល គឺនៅពេលតែមួយ ដែលជាហេតុធ្វើឲ្យផលិតផលរបស់ពួកគាត់ជន់ ហើយពួកគាត់មិនទាន់ចេះទុកដាក់ផលិតផល និងស្វែងរកទីផ្សារដើម្បីលក់ទៅខាងក្រៅទេ។ ដូច្នេះគម្រោងនេះមានគោលដៅដូចខាងក្រោម៖

- គំនិតពិសោធន៍ដើម្បី "កាត់បន្ថយភាពក្រីក្រក្នុងចំណោមតំបន់ជនបទក្រីក្រដោយធ្វើឲ្យជំនាញប្រសើរឡើងលើបច្ចេកទេសក្រោយប្រមូលផល នៃការកែច្នៃ ការបង្ការទុក ឲ្យបានយូរ ការប្រមូលផល និងរក្សាធ្វើបន្តដោយកែច្នៃ និងផ្ទេរផលិតផលដែលមានចំនួនលើសតម្រូវការឲ្យទៅជាផលិតផលថ្មី និងមានសារៈសំខាន់នៅទីផ្សារ"។

**របៀបវារៈទី៥**

បន្ទាប់មក ឯកឧត្តមប្រធាន អង្គប្រជុំក៏បានអនុញ្ញាតឲ្យឯកឧត្តម **ហុង ជឿន** ជាតំណាងទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ធ្វើបទបង្ហាញអំពីផែនការការងាររបស់ ទ.ជ.ម.ក ហើយក្នុងនោះឯកឧត្តម **ហុង ជឿន** បានលើកឡើងនូវចំណុចសំខាន់មួយចំនួនដូចខាងក្រោម ៖

គោលបំណងក្នុងការបង្កើតឲ្យមាន ទ.ជ.ម.ក គឺដើម្បីផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពដល់អ្នកស្វែងរកការងារធ្វើ និយោជក និយោជិត អ្នករៀបចំគោលនយោបាយ និងផ្តល់ការ

បណ្តុះបណ្តាលជំនាញ ការអប់រំ និងអភិវឌ្ឍន៍ និងសាធារណៈជនទូទៅ។ ហើយជារួម ទ.ជ.ម.ក មានតួនាទី និងភារៈកិច្ចចម្បងៗដូចតទៅ៖

- សម្របសម្រួល និងរៀបចំឲ្យមានសេវាព័ត៌មានការងារ និងមុខរបរ និងការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- ផ្តល់សេវាព័ត៌មានទីផ្សារការងារប្រកបដោយប្រសិទ្ធភាព
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារឲ្យសមស្របទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ចសង្គមនាពេលបច្ចុប្បន្ន និងទៅអនាគត
- ជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ និងមុខរបរ និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- សហប្រតិបត្តិការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការ សង្គមស៊ីវិល ដែលត្រូវការកម្លាំងពលកម្ម និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីលើកអនុសាសន៍ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ផ្តល់ទិន្នន័យជាក់លាក់ស្តីពីព័ត៌មានទីផ្សារការងារ

ជាបន្តឯកឧត្តមក៏បានលើកឡើងអំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ ទ.ជ.ម.ក និងផែនការ ការងាររបស់ ទ.ជ.ម.ក សម្រាប់ឆ្នាំ២០១០-២០១២ ដែលមានចក្ខុវិស័យក្នុងការរួមចំណែក សម្រេចគោលដៅរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារការងារ បង្កើនការចូលរួមក្នុងទីផ្សារការងារ កាត់បន្ថយនិកម្មភាព ជំរុញកំណើន និងកាលានុវត្តភាព និងជាយថាហេតុជួយកាត់បន្ថយភាពក្រីក្រ។ ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ផែនការការងារបានកំនត់នូវបេសកកម្មធំៗចំនួន៣ ដែលមានទិសដៅសំខាន់ៗចំនួន៥ អមដោយសកម្មភាពការងារចំនួន៤៤សកម្មភាព និងមានលទ្ធផលរំពឹងទុកចំនួន១២។

ជាការឆ្លើយតប **ឯកឧត្តមប្រធាន** អង្គប្រជុំបានធ្វើការចាប់អារម្មណ៍លើបេសកកម្មទាំង ៣ចំនុចរបស់ ទ.ជ.ម.ក ដូចខាងក្រោម៖

- ផ្តល់សេវាការងារជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព
- ប្រមូលព័ត៌មាន វិភាគ និងផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ
- ជំរុញការបន្សុីគ្នានូវជំនាញរបស់កម្លាំងពលកម្មជាមួយនឹងតម្រូវការទីផ្សារ

បន្ថែមលើនេះ **ឯកឧត្តមប្រធាន** ក៏បានលើកឡើងនូវការស្នើសុំតែងតាំងសមាសភាព ថ្នាក់ដឹកនាំរបស់ ទ.ជ.ម.ក ដើម្បីចាប់ផ្តើមដាក់ឲ្យដំណើរការពីពេលនេះតទៅស្របតាម អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលមកដល់ពេលបច្ចុប្បន្ននេះពុំទាន់មានសមាសភាពថ្នាក់ដឹកនាំនៅឡើយ។

<u>របៀបវារៈទី៦</u>

ជាកិច្ចបន្ត ឯកឧត្តមប្រធាន អង្គប្រជុំក៏បានអនុញ្ញាតឲ្យឯកឧត្តម **ហេង សួរ** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើបទបង្ហាញអំពីគេហទំព័ររបស់ (ទ.ជ.ម.ក) បន្ទាប់មកឯកឧត្តម **ហេង សួរ** បានលើកឡើងនូវចំនុចសំខាន់មួយចំនួនរបស់គេហទំព័រថ្មីនេះ៖

- ជាគេហទំព័រថ្មីដែលអាចឲ្យភាគីទាំងបីរួមមាន អ្នកស្វែងរកការងារធ្វើ អ្នកផ្តល់ការងារ និងអ្នកផ្តល់ការបណ្តុះបណ្តាលអាចស្វែងរកព័ត៌មានពីគ្នាទៅវិញទៅមក
- បង្កើតធនាគារទិន្នន័យអ្នកស្វែងរកការងារធ្វើ ផ្តល់នូវព័ត៌មានទីផ្សារការងារ និងការងាររំពឹងទុកនាពេលអនាគត
- មានរបាយការណ៍ផ្តួងជាស្វ័យប្រវត្តិ

របៀបវារៈទី៧

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឲ្យ លោកស្រី **សៅ សុគន្ធកេសរា** ប្រធានការិយាល័យមូលនិធិជាតិបង្កើតមុខរបរដោយខ្លួនឯង ធ្វើសេចក្តីរាយការណ៍សង្ខេបជូនអង្គប្រជុំអំពី សកម្មភាព និងលទ្ធផល ដែលមូលនិធិបង្កើតមុខរបរដោយខ្លួនឯងបានអនុវត្តកន្លងមកៈ

- ដើមទុនរបស់មូលនិធិបង្កើតមុខរបរដោយខ្លួនឯងមានចំនួន ១,១៦៨,000 USD(មួយលានមួយរយហុកសិបប្រាំបីពាន់ ដុល្លាគត់)
- អនុវត្តបានចំនួន ០៩ ជំហាន ទៅលើ ១៦ខេត្ត និងរាជធានីភ្នំពេញ
- ផ្តល់ឥណទានដល់សិស្ស-សិក្ខាកាមដែលបានរៀនចប់មានចំនួន ៥,៧៥៥នាក់ ក្នុងនោះមានស្ត្រីចំនួន ៣,៧០១នាក់ ស្មើនឹង ៦៤.៣១%
- ទឹកប្រាក់ដែលមានជាក់ស្តែងនៅក្នុងគណនីគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩គឺៈ ១,២៣៨,000 USD (មួយលាន ពីររយសាមសិបប្រាំបីពាន់ ដុល្លាគត់)។

របៀបវារៈទី៨

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំក៏បានអនុញ្ញាតឲ្យ ឯកឧត្តម **ពេជ សោភ័ន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល បានរាយការណ៍ជូនអង្គប្រជុំអំពីសំណើសុំការអនុម័តលើកញ្ចប់ថវិកាសម្រាប់សាងសង់វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគខេត្តតាកែវ ហើយឯកឧត្តម **ពេជ សោភ័ន** បានជម្រាបជូននៅក្នុងគម្រោងសាងសង់វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគខេត្តតាកែវ ត្រូវបង្កើតគណៈកម្មការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា និងបង្កើតអង្គភាពលទ្ធកម្មសាធារណៈនៅក្រោម NTB ដែលគម្រោងសាងសង់នេះមានទឹកប្រាក់សរុប ៥៩៦,២៦៧.៣៧ USD។ ឯកឧត្តមបានស្នើសុំអង្គប្រជុំដើម្បីពិនិត្យ និងធ្វើការអនុម័ត។

លទ្ធផលនៃអង្គប្រជុំ

-អង្គប្រជុំបានផ្តល់អនុសាសន៍លើៈ

- គួរប្រើប្រាស់នូវគេហទំព័រថ្មី ប៉ុន្តែ ទ.ជ.ម.ក ត្រូវពិនិត្យសម្រេចអំពីការរក្សាទុក ឬ បញ្ឈប់លែងឲ្យដំណើរការគេហទំព័រចាស់របស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ទំនាក់ទំនងជាមួយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (NiDA)ដើម្បីរក្សា Server និងទុកឯកសារប្រកបដោយសុវត្ថិភាព

-អង្គប្រជុំបានអនុម័តលើ ៖

- កញ្ចប់ថវិកាសម្រាប់សាងសង់វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគខេត្តតាកែវ
- ឯកភាពលើសំណើសុំតែងតាំងសមាសភាពថ្នាក់ដឹកនាំរបស់ ទ.ជ.ម.ក
- **ឯកឧត្តមប្រធាន** អង្គប្រជុំក្នុងនាមអ្នកគ្រប់គ្រងកិច្ចសន្យាបានចុះហត្ថលេខាលើកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវារបស់ ទ.ជ.ម.ក ជាមួយឯកឧត្តម **ហុង ធឿន** ក្នុងនាមជាអ្នកផ្តល់សេវាសម្រាប់រយៈពេល០១ (មួយ)ឆ្នាំ
- ឯកភាពលើសេចក្តីព្រាងស្តីពីគេហទំព័ររបស់ ទ.ជ.ម.ក

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជំនាញការជាតិ និងអន្តរជាតិ ដែលបានចូលរួមចំណែកផ្តល់យោបល់ ក៏ដូចជាចែករំលែកបទពិសោធន៍ការងារល្អៗកន្លងមក និងសុំឲ្យក្រុមការងាររបស់ NTB យកចិត្តទុកដាក់បន្តការងារតទៅមុខទៀត។

ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ពីររសៀល ថ្ងៃខែឆ្នាំដដែល ស្ថិតនៅក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់ ៕

លេខាកត់ត្រា

**ហ៊ីង ស៊ីដេត**

បានឃើញ និង ឯកភាព

ប្រធានអង្គប្រជុំ

សុង ភេង